ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០២២/២០ - ហ្វូដ មីរ៉េ ថយស៍
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អាន វីរៈ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **គង់ ផល្លះ**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ហ្វូដ មីរ៉េ ថយស៍**

អាសយដ្ឋាន ៖ ភូមិអន្លង់គងង សង្កាត់ព្រែស ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៩២ ៩៨ ៩៨ ០៩ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក Zheng Lun | ប្រធានផលិតកម្ម |
| ២- លោកស្រី ដួង ចន្ទី | ប្រធានរដ្ឋបាល |
| ៣- លោក ហ៊ិន សុវិសាល | អ្នកបកប្រែ |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ហ្វូដ មីរ៉េ ថយស៍**

អាសយដ្ឋាន ៖ ភូមិអន្លង់គងង សង្កាត់ព្រែស ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៨៦០ ៧១៥/ ០៨៩ ៩៦ ១៤ ៤៥ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក អ៊ិន ដារ៉ា | ប្រធានសហព័ន្ធសហជីពស្មារតីកម្មករឯករាជ្យ |
| ២- លោក អ៊ិន មករា | អគ្គសហព័ន្ធសហជីពស្មារតីកម្មករឯករាជ្យ |
| ៣- លោកស្រី ឈន ចាន់នី | ប្រធានសហជីព(មូលដ្ឋាន) |
| ៤- លោក ជី ហុងលី | អនុប្រធានសហជីព(មូលដ្ឋាន) |

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak-II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

៥- កញ្ញា សុខ កាមួយ ហិរញ្ញិកសហជីព

៦- លោកស្រី រុំ ស្រីម៉ិច លេខាសហជីព

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- (ចំណុចទី១) តំណាងកម្មករនិយោជិតនៅតែទាមទារ សុំឱ្យក្រុមហ៊ុនបន្តកិច្ចសន្យាការងារកម្មករនិយោជិត ដែលក្រុមហ៊ុនបានបញ្ចប់កិច្ចសន្យា ឱ្យពួកគាត់បន្តកិច្ចសន្យាការងារឡើងវិញ។

២- (ចំណុចទី៣) តំណាងកម្មករនិយោជិតនៅតែទាមទារ សុំឱ្យក្រុមហ៊ុនដកអ្នកគ្រប់គ្រងឈ្មោះ ដួង ចន្ទី ចេញពីក្រុមហ៊ុនដដែល។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ១៨១ ក.ប/ប្រ.ក.រ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩(អាណត្តិទី១៧)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហ្វូដ មីរ៉ៃ ថយស៍ លេខ ៣៤៧ ក.ប/អក/វក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃសុក្រ ១១កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ នាយកដ្ឋានវិវាទការងារបានទទួលបណ្តឹងតាមទូរសព្ទរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ហ្វូដ មីរ៉ៃ ថយស៍ ស្តីពីកម្មករនិយោជិតចំនួន ២៧៤នាក់ ក្នុងចំណោមកម្មករនិយោជិត ២៧៤ នាក់ នៃក្រុមហ៊ុននេះធ្វើកូដកម្មទាមទារសុំឱ្យក្រុមហ៊ុន ហ្វូដ មីរ៉ៃ ថយស៍ ដោះស្រាយលក្ខខណ្ឌការងារចំនួន ៣ចំណុច ឱ្យបានប្រសើរ។ បន្ទាប់ពីបានទទួលបណ្តឹងនេះរួចមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ១ចំណុច។ ចំណុចមិនសះជាចំនួន ២ចំណុច ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ

២០២០ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហ្គូដ មីរ៉ែ ថយស៍ លេខ ៣៤៧ កប/អក/វក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០។ នៅមុនពេលក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលលិខិតមួយច្បាប់ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ហ្គូដ មីរ៉ែ ថយស៍ ដែលមានកម្មវត្ថុស្តីពីសំណើសុំចេញសេចក្តីបញ្ជាដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិតនៅក្រុមហ៊ុន ហ្គូដ មីរ៉ែ ថយស៍។ ហេតុនេះ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាលេខ ០០២/២០ កបអ. ឱ្យផ្អាកជាបន្ទាន់ នូវការធ្វើកូដកម្មរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ហ្គូដ មីរ៉ែ ថយស៍ រហូតដល់នីតិវិធីនៃអាជ្ញាកណ្តាលត្រូវបានបញ្ចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីព្រឹកថ្ងៃទី១ ខែមេសា ឆ្នាំ២០២០ តទៅ តាមវេនរបស់ខ្លួន។ ក្រោយពីទទួលបានសេចក្តីបញ្ជារបស់ក្រុមប្រឹក្សា-អាជ្ញាកណ្តាល កម្មករនិយោជិតបានចូលធ្វើការធម្មតាវិញតាមសេចក្តីបញ្ជាខាងលើ។

លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សាលើករណីមិនសះជាទាំង ២ចំណុច នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ៨ និង ៣០នាទី ព្រឹក។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សា-អាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមស្វែងរកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ២ចំណុចនេះ និងបានធ្វើការផ្សះផ្សាលើចំណុចវិវាទនេះបន្ថែមទៀត ដោយក្នុងនោះភាគីកម្មករនិយោជិតបានសម្រេចដកចំណុចវិវាទទី២ ចេញពីការងារទាមទារនៅក្នុងសំណុំរឿងនេះ។ ហេតុនេះ ក្រុមប្រឹក្សា-អាជ្ញាកណ្តាលនឹងពិចារណាចំណុចវិវាទដែលនៅសល់តែមួយចំណុចប៉ុណ្ណោះ គឺចំណុចវិវាទទី១។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ផ្តល់ភស្តុតាង និងថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

កាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល យ៉ាងយូរត្រឹមថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិរបស់ឈ្មោះ Kim Hyangchan នាយកក្រុមហ៊ុន ហ្គូដ មីរ៉ែ ថយស៍ គោរពជូនប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំផ្ទេរសិទ្ធិជូនលោក Zheng Lun ជានាយកគ្រប់គ្រង មានសិទ្ធិ និងអំណាចពេញលេញក្នុងការដោះស្រាយបញ្ហាវិវាទការងារក្នុងនាមតំណាងឱ្យម្ចាស់ ឬនាយកក្រុមហ៊ុន ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០។

២- លិខិតរបស់ក្រុមហ៊ុន ហ្វូដ មីរ៉ៃ ថយស៍ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំចេញសេចក្តីបញ្ជា ដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិត នៅក្រុមហ៊ុន ហ្វូដ មីរ៉ៃ ថយស៍ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០។

៣- ប័ណ្ណប៉ាតង់ឆ្នាំ២០២០ ក្រុមហ៊ុន ហ្វូដ មីរ៉ៃ ថយស៍ លេខ PTS 2020031007 អពដ ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០២០។

៤- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន ហ្វូដ មីរ៉ៃ ថយស៍ លេខ MOC-១៧៦៦៤៤៤ ពណ.ចបព ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៣។

៥- លក្ខន្តិកៈក្រុមហ៊ុន ហ្វូដ មីរ៉ៃ ថយស៍ បានតម្កល់ទុកលេខ ៤១០៥/២០១៣ ពណ.ចបព ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៣ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម។

៦- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ហ្វូដ មីរ៉ៃ ថយស៍ ចុះទិដ្ឋាការ លេខ ១៩២ កប.អក.អធក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ដោយនាយកដ្ឋានអធិការកិច្ចការងារ។

៧- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ហ្វូដ មីរ៉ៃ ថយស៍ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០។

៨- ឯកសារស្តីពីការជូនដំណឹងអំពីការមិនបន្តកិច្ចសន្យាដល់កម្មករនិយោជិត ដែលដល់កិច្ចសន្យា ដោយមូលហេតុ Buyers ផ្អាកការបញ្ជាទិញ។

៩- ឯកសារជាភាសាបរទេស។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិត ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ របស់ កម្មករនិយោជិតនៃក្រុមហ៊ុន ហ្វូដ មីរ៉ៃ ថយស៍ គោរពជូន លោក អ៊ុន ដារ៉ា ប្រធានសហព័ន្ធ សហជីពស្មារតីកម្មករឯករាជ្យ ស្តីពីសូមពឹងពាក់ និងផ្ទេរសិទ្ធិឱ្យលោកប្រធានជួយដោះស្រាយលក្ខខណ្ឌការងារដែលក្រុមហ៊ុនមិនបានអនុវត្ត។

២- លិខិតលេខ ១៤៥ ក.ប/វក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៧ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបញ្ជាក់ថា សហជីពស្មារតីកម្មករឯករាជ្យនៃក្រុមហ៊ុន ហ្វូដ មីរ៉ៃ ថយស៍ ជាអង្គការវិជ្ជាជីវៈមួយត្រូវបានចុះបញ្ជីនៅនាយកដ្ឋានវិវាទការងារ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ។

៣- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ សហជីពស្មារតីកម្មករឯករាជ្យ នៃក្រុមហ៊ុន ហ្វូដ មីរ៉ៃ ថយស៍ លេខ២២៤ ក.ប/វ.ប.វ.ក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៧។

៤- បង្កាន់ដៃទទួលពាក្យស្នើសុំចុះបញ្ជីសហជីពស្មារតីកម្មករឯករាជ្យ នៃក្រុមហ៊ុន ហ្វូដ មីរ៉ៃ លេខ ០៣២/២០ កប/អកវក/បទព ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ របស់នាយកដ្ឋានវិវាទការងារ។

៥- លក្ខន្តិកៈនៃសហជីពស្មារតីកម្មករឯករាជ្យ នៃក្រុមហ៊ុន ហ្វូដ មីរ៉ៃ ថយស៍ ចុះទិដ្ឋាការលេខ ១១២១៧០១២៤ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៧។

៦- លិខិតចុះថ្ងៃសៅរ៍ ៧កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ ២០២០ របស់ឈ្មោះ ឈន ចាន់នី ជាប្រធានសហជីពស្មារតីកម្មករឯករាជ្យ នៃក្រុមហ៊ុន ហ្វូដ

THE ARBITRATION COUNCIL

មីរ៉ែ គោរពជូន លោកនាយកក្រុមហ៊ុន ហ្គូដមីរ៉ែ ថយស៍ ស្តីពីជូនដំណឹងស្តីពីការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពស្មារតីកម្មករឯករាជ្យនៃក្រុមហ៊ុន ហ្គូដ មីរ៉ែ ថយស៍(អាណត្តិទី២)។

៧- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ហ្គូដ មីរ៉ែ ថយស៍ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០។

៨- លិខិតចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ របស់សហព័ន្ធសហជីពស្មារតីកម្មករឯករាជ្យ គោរពជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសារណាសង្ខេប។

៩- បញ្ជីឈ្មោះកម្មករដែលក្រុមហ៊ុនផ្តាច់កិច្ចសន្យា។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ហ្គូដ មីរ៉ែ ថយស៍លេខ ៣៤៧ ក.ប/អក/វក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ហ្គូដ មីរ៉ែ ថយស៍ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហ្គូដ មីរ៉ែ ថយស៍ លេខ ០០៥/២០កប/អប/លបវ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ របស់នាយកដ្ឋានវិវាទការងារ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- សេចក្តីបញ្ជា លេខ ០០២/២០ កបអ. ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ របស់ក្រុមប្រឹក្សាអាជ្ញា-កណ្តាល។

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ១៣៤ កប/អក/វក/លកអ. ចុះថ្ងៃពុធ ៩កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០។

៣- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១៣៥ កប/អក/វក/លកអ. ចុះថ្ងៃពុធ ៩កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន ហ្គូដ មីរ៉ែ ថយស៍ គឺជាក្រុមហ៊ុនដែលមានសកម្មភាពចម្បងផ្នែកផលិតសម្លៀកបំពាក់ និងសម្ភារៈក្មេងប្រើប្រាស់ ទទួលបានវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មលេខ ០០០១៣៩១៧ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៣។ ក្រុមហ៊ុននេះមានជួលកម្មករនិយោជិតសរុបចំនួន ២៧៤ នាក់ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមរវាងក្រុមហ៊ុន ហ្គូដ មីរ៉ែ ថយស៍)*។

- យោងតាមបញ្ជីឈ្មោះកម្មករនិយោជិតដែលក្រុមហ៊ុនផ្តាច់កិច្ចសន្យា (កម្មករនិយោជិតដែលមានកិច្ចសន្យាការងារមានថិរវេលាមិនកំណត់) ជាដើមបណ្តឹងសរុបចំនួន ៤៧នាក់ ដោយក្នុងនោះក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញមានកម្មករនិយោជិតចំនួន ២នាក់ (ឈ្មោះ អឿន ស្រីនាថ អត្តលេខ ១៤១១០០២ និងឈ្មោះ ទុំ ចន្ទី អត្តលេខ ១៥០៣០០៦) មិនមានឈ្មោះនៅក្នុងបញ្ជីឈ្មោះដែលនិយោជកត្រូវបញ្ចប់កិច្ចសន្យាការងារនោះទេ និងកម្មករនិយោជិតចំនួន ១នាក់ (ឈ្មោះ អាន់ សុភាព អត្តលេខ ១៧០២០០៤) ជាស្ត្រីមានផ្ទៃពោះ ដែលនិយោជកបានបន្តកិច្ចសន្យាការងារគាត់រួចហើយ។ ហេតុនេះ កម្មករនិយោជិតដែលមានកិច្ចសន្យាមានថិរវេលាមានកំណត់ ដែលជាដើមបណ្តឹងសរុបចំនួន ៤៤នាក់ ប៉ុណ្ណោះ។

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបន្តកិច្ចសន្យាការងារកម្មករនិយោជិត ដែលក្រុមហ៊ុនបានបញ្ចប់កិច្ចសន្យាឱ្យពួកគាត់បន្តកិច្ចសន្យាការងារឡើងវិញ**

- ភាគីទាំងពីរទទួលស្គាល់ថា ៖
  - ការអនុវត្តនៅក្នុងក្រុមហ៊ុន និយោជកប្រើកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាចំនួន ៣ ខែម្តង ចំពោះកម្មករនិយោជិតធម្មតា។ នៅពេលកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ៣ ខែម្តង ដល់កាលកំណត់ម្តងៗ និយោជកតែងតែទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យា ចំនួន ៥ ភាគរយ ជូនកម្មករនិយោជិត។
  - នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ និយោជកបានជូនដំណឹងស្តីពីការមិនបន្តកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ៦៤នាក់ ដែលកិច្ចសន្យាការងារនោះនឹងត្រូវដល់កាលកំណត់នៅក្នុងខែមេសា ឆ្នាំ២០២០នេះ (នៅថ្ងៃផ្សេងៗគ្នា)។
  - ក្នុងចំណោមកម្មករនិយោជិតទាំង ៦៤នាក់ខាងលើ គឺមានកម្មករនិយោជិតចំនួន ២០នាក់ ដែលមានកិច្ចសន្យាការងារតិចជាង ២ឆ្នាំ និងមានកម្មករនិយោជិតចំនួន ៤៤នាក់ ដែលមានកិច្ចសន្យាការងារលើសពី ២ឆ្នាំ (បញ្ជីឈ្មោះកម្មករនិយោជិតដែលភាគីនិយោជកបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០)។
  - ចំពោះកម្មករនិយោជិតដែលមានកិច្ចសន្យាការងារលើសពី ២ឆ្នាំឡើងទៅ ភាគីនិយោជកឯកភាពផ្លាស់ប្តូរប្រភេទកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ទៅជាកិច្ចសន្យាមានថិរវេលាមិនកំណត់ ជូនកម្មករនិយោជិតស្របតាមសេចក្តីណែនាំលេខ ០៥០/១៩ ក.ប/ស.ណ.ន.គ.ប.ក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការកំណត់ប្រភេទកិច្ចសន្យាការងារ។
  - ចំពោះកម្មករនិយោជិតដែលមានកិច្ចសន្យាការងារតិចជាង ២ឆ្នាំ (កិច្ចសន្យាការងារដែលមានកំណត់ថិរវេលា) និយោជកបានជូនដំណឹងមិនបន្តកិច្ចសន្យាការងារដោយទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាចំនួន ៥ភាគរយ, ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ, និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករនិយោជិត។ នៅពេលណាដែលក្រុមហ៊ុនមានការងារធ្វើនោះ និយោជកនឹងជ្រើសរើសពួកគាត់មកធ្វើការងារវិញ។ ភាគីកម្មករនិយោជិតក៏ព្រមទទួលយកការផ្តល់ឱ្យរបស់ភាគីនិយោជក។

THE ARBITRATION COUNCIL

- ០ គិតមកត្រឹមថ្ងៃសវនាការ កម្មករនិយោជិតទាំង ៦៤នាក់ ដែលនិយោជកសម្រេចមិនបន្តកិច្ចសន្យាការងាររបស់ពួកគាត់ គឺនៅតែបំពេញការងារធម្មតាដដែល រហូតដល់ថ្ងៃដែលកិច្ចសន្យាការងារគាត់ដល់ពេលកំណត់។

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារឱ្យនិយោជកអនុវត្តតាមសេចក្ដីណែនាំលេខ ០៥០/១៩ ក.ប/ស.ណ.ន.គ.ប.ក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ ស្ដីពីការកំណត់ប្រភេទកិច្ចសន្យាការងាររបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ចំពោះកម្មករនិយោជិតមានកិច្ចសន្យាកាងារមានថិរវេលាមិនកំណត់ និងព្យួរកិច្ចសន្យាការងារកម្មករនិយោជិតតាមសេចក្ដីណែនាំលេខ ០១៤/២០ ក.ប/ស.ណ.ន.ខ.ល. ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ ស្ដីពីការព្យួរកិច្ចសន្យាការងារ ការចុះឈ្មោះចូលរៀនជំនាញទន់ និងការផ្អាកបង់ភាគទានប.ស.ស សម្រាប់វិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ និងកាបូបដែលរងផលប៉ះពាល់ពីកង្វះខាតវត្ថុធាតុដើមដោយសារជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរខូវីដ១៩។ ម្យ៉ាងទៀត និយោជកត្រូវគោរពតាមសេចក្ដីអំពាវនាវរបស់ក្រសួងការងារចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០២០ ដោយនិយោជកមិនអាចយកលេសដើម្បីបញ្ចប់កិច្ចសន្យាការងារកម្មករនិយោជិតបាននោះទេ។
- ភាគីនិយោជករក្សាគោលជំហរ មិនអាចផ្ដល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយមូលហេតុថា ៖
  - ០ យោងតាមលិខិតនៃការបញ្ជាទិញចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ចំពោះខែមេសា គឺមានចំនួន ៣០.០៣២ គុក្កតា និងខែឧសភា គឺមានចំនួន ៤.៩១៨ តុក្កតា។ ជាធម្មតា គឺមានការបញ្ជាទិញចំនួន ១១០.០០០តុក្កតា ទៅ១២០.០០០ តុក្កតា ក្នុងមួយខែ។ បញ្ហាចម្បងនៅក្នុងក្រុមហ៊ុននោះ គឺមិនមែនខ្វះវត្ថុធាតុដើមនោះទេ គឺក្រុមហ៊ុនមិនមានការបញ្ជាទិញ ដោយសារតែការរីករាលដាលនៃជម្ងឺឆ្លងផ្លូវដង្ហើមកូវីដ-១៩។
  - ០ ប្រសិនបើមានការងារធ្វើឡើងវិញ និយោជកនឹងពិចារណាជ្រើសរើសយកកម្មករនិយោជិតចូលធ្វើការងារវិញ។
- នៅថ្ងៃសវនាការភាគីនិយោជកបានបញ្ជាក់ថា ចំពោះកម្មករនិយោជិតទាំង ៤៤នាក់ ដែលមានកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ គឺកំពុងនៅធ្វើការធម្មតា។

## ហេតុផលនៃសេចក្ដីសម្រេច

**ចំណុចវិវាទទី១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបន្តកិច្ចសន្យាការងារកម្មករនិយោជិតដែលនិយោជកបានបញ្ចប់កិច្ចសន្យា ឱ្យពួកគាត់បន្តកិច្ចសន្យាការងារឡើងវិញ**

ពាក់ព័ន្ធនឹងការទាមទាររបស់ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកបន្តកិច្ចសន្យាការងារកម្មករនិយោជិតដែលនិយោជកបានបញ្ចប់កិច្ចសន្យា ឱ្យពួកគាត់បន្តកិច្ចសន្យាការងារឡើងវិញ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្ដាលមានយុត្តាធិការក្នុងការដោះស្រាយចំណុចទាមទារនេះដែរឬទេ?

កថាខណ្ឌទី១ មាត្រា ៣១២ នៃច្បាប់ស្ដីពីការងារចែងថា ៖ "*ក្រុមប្រឹក្សាអាជ្ញាកណ្ដាល គ្មានសមត្ថកិច្ចពិនិត្យបញ្ហាដទៃ ក្រៅពីបញ្ហាដែលមានបញ្ជាក់ក្នុងកំណត់ហេតុមិនព្រមសះជា ឬបញ្ហាដែលកើតឡើងក្រោយការធ្វើកំណត់ហេតុជាផលវិបាកផ្ទាល់នៃការវិវាទនោះតែប៉ុណ្ណោះ។*"

ប្រការ ៣៣ នៃប្រកាសលេខ ៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលចែងថា៖ *"អំណាចរបស់ក្រុមអាជ្ញាកណ្តាលក្នុងការពិចារណាទៅលើវិវាទមួយ ត្រូវកំរិតត្រឹមតែបញ្ហាទាំងឡាយណាដែលមានក្នុងកំណត់ហេតុនៃការផ្សះផ្សាមិនបានសះជា រួមទាំងបញ្ហាជាផលវិបាកផ្ទាល់នៃវិវាទនោះ ដែលកើតឡើងក្រោយការធ្វើកំណត់ហេតុ។"*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ បានបកស្រាយកថាខណ្ឌទី១ មាត្រា ៣១២ នៃច្បាប់ស្តីពីការងារ និងប្រការ ៣៣ នៃប្រកាសលេខ ៩៩ ខាងលើថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាតែចំណុចវិវាទដែលមាននៅក្នុងរបាយការណ៍មិនសះជាប៉ុណ្ណោះ។ ចំណែកឯចំណុចវិវាទដែលមិនមាននៅក្នុងរបាយការណ៍មិនសះជា ដែលភាគីលើកឡើងនៅក្នុងសវនាការ បញ្ជាក់ពីការទាមទារបន្ថែម ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចធ្វើការពិចារណាបាន លុះត្រាតែចំណុចវិវាទនោះ គឺជាបញ្ហាកើតក្រោយការធ្វើកំណត់ហេតុ ដែលជាផលវិបាកផ្ទាល់នៃការវិវាទនោះតែប៉ុណ្ណោះ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៤២/០៧-សោជន៍ បេ ហេតុផលនៃចំណុចវិវាទទី៣, លេខ ០៦/០៨-យើង ឡែន ហេតុផលនៃចំណុចវិវាទទី២, និងលេខ ០៣៨/១៧-ផាក ស៊ុន នីធីង ហ្វេកធើរីង លីមីធីត ហេតុផលនៃចំណុចវិវាទទី១)*

លើសពីនេះទៀត នៅក្នុងសំណុំរឿងលេខ ១០/០៣-ហ្សាក់ស៊ីនតិច ហេតុផលនៃចំណុចវិវាទទី២ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា *"ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្កើតឡើងដើម្បីដោះស្រាយជម្លោះការងារ មិនមែនដើម្បីដោះស្រាយបញ្ហាដែលមិនទាន់កើតឡើងនោះទេ" ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៤/០៦-សេង យ៉ុង ហេតុផលចំណុចនៃវិវាទទី២, លេខ ៥៨/០៧-៨ ស្តារ ស្គត វែរ ហេតុផលចំណុចនៃវិវាទទី១, លេខ ១៥៥/១៣-កាតាត ហេតុផលនៃចំណុចវិវាទទី៤, លេខ ២២២/១៦-ហ្វូហ្វូ ហេតុផលនៃចំណុចវិវាទទី៥, លេខ ០៤៨/១៧-ណានតាយ ហ្គាមេន ហ្វាក់ធើរី (ខេមបូឌា) លីមីធីត ហេតុផលនៃចំណុចវិវាទទី៥, និងលេខ ០១៧/១៩-ជាវ ហ៊ុយ អ៊ិនជាសស្ទ្រៀល ហេតុផលនៃចំណុចវិវាទទី៩)*

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

យោងតាមអង្គហេតុខាងលើគិតមកត្រឹមថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មានកម្មករនិយោជិតចំនួន ៦៤នាក់ ដែលនិយោជកបានជូនដំណឹងអំពីការមិនបន្តកិច្ចសន្យាការងារ ប៉ុន្តែ មិនទាន់មានកម្មករនិយោជិតណាម្នាក់បាត់បង់ការងារនោះទេ គឺពួកគាត់កំពុងបំពេញការងារធម្មតាដដែល។ ដូចនេះ មានន័យថា វិវាទពាក់ព័ន្ធនិងការបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិត គឺមិនទាន់មានកើតឡើងនោះទេ។ ដូច្នេះ វាជាវិវាទអំពីអនាគត។

ទោះបីជាយ៉ាងនេះក៏ដោយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ក្នុងចំណោមកម្មករនិយោជិតទាំង ៦៤នាក់ ខាងលើ គឺមានកម្មករនិយោជិតចំនួន ២០នាក់ ដែលមានកិច្ចសន្យាការងារតិចជាង ២ឆ្នាំ (កិច្ចសន្យាការងារដែលមានកំណត់ថិរវេលា) និងមានកម្មករនិយោជិតចំនួន ៤៤នាក់ ដែលមានកិច្ចសន្យាការងារលើសពី ២ឆ្នាំ (កិច្ចសន្យាការងារមានថិរវេលាមិនកំណត់)។ ចំពោះកម្មករនិយោជិតចំនួន ២០នាក់ ដែលមានកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ភាគីកម្មករនិយោជិតឯកភាពទទួលយកការផ្តល់ឱ្យរបស់និយោជកនូវប្រាក់បំណាច់បញ្ចប់កិច្ចសន្យាចំនួន ៥ភាគរយ, ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករនិយោជិត ហើយសន្យាថា នៅពេលណាដែលក្រុមហ៊ុនមានការងារធ្វើនោះ

THE ARBITRATION COUNCIL

និយោជកនឹងជ្រើសរើសពួកគាត់មកធ្វើការងារវិញ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនពិចារណាការទាមទារចំពោះកម្មករនិយោជិតដែលមានកិច្ចសន្យាការងារដែលមានកំណត់ថិរវេលានោះទេ។

ដោយឡែក ចំពោះកម្មករនិយោជិតចំនួន ៨៤នាក់ ដែលមានកិច្ចសន្យាការងារមានថិរវេលាមិនកំណត់វិញនោះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ពួកគាត់កំពុងនៅធ្វើការធម្មតានៅឡើយ ហើយនៅក្នុងសវនាការភាគីកម្មករនិយោជិតបានទាមទារ ឱ្យនិយោជកអនុវត្តតាមសេចក្តីណែនាំលេខ ០៥០/១៩ ក.ប/ស.ណ.ន.គ.ប.ក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការកំណត់ប្រភេទកិច្ចសន្យាការងារ ចំពោះកម្មករនិយោជិតមានកិច្ចសន្យាកាងារមានថិរវេលាមិនកំណត់ និងព្យួរកិច្ចសន្យាការងារកម្មករនិយោជិតតាមសេចក្តីណែនាំលេខ ០១៤/២០ ក.ប/ស.ណ.ន.ខ.ល. ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការព្យួរកិច្ចសន្យាការងារ ការចុះឈ្មោះចូលរៀនជំនាញទន់ និងការផ្អាកបង់ភាគទាន ប.ស.ស សម្រាប់វិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ និងកាបូបដែលរងផលប៉ះពាល់ពីកង្វះខាតវត្ថុធាតុដើមដោយសារជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរខូវីដ១៩។ ប៉ុន្តែ យោងតាមរបាយការណ៍លេខ ៣៤៧ ក.ប/អក/វក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហ្វូង មីរ៉ៃ ថយស៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកមិនឃើញមានចំណុចទាមទារដូចចំណុចទាមទារខាងលើនោះទេ។

ម្យ៉ាងទៀត ទាក់ទងនឹងការលើកឡើងរបស់ភាគីកម្មករនិយោជិតនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា ពិតជាមានសេចក្តីណែនាំលេខ ០៥០/១៩ ក.ប/ស.ណ.ន.គ.ប.ក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការកំណត់ប្រភេទកិច្ចសន្យាការងារ និងសេចក្តីណែនាំលេខ ០១៤/២០ ក.ប/ស.ណ.ន.ខ.ល. ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការព្យួរកិច្ចសន្យាការងារ ការចុះឈ្មោះចូលរៀនជំនាញទន់ និងការផ្អាកបង់ភាគទាន ប.ស.ស សម្រាប់វិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ និងកាបូបដែលរងផលប៉ះពាល់ពីកង្វះខាតវត្ថុធាតុដើម ដោយសារជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរខូវីដ១៩ ប្រាកដមែន។ ក៏ប៉ុន្តែ យោងតាមកថាខណ្ឌទី១ មាត្រា ៣១២ នៃច្បាប់ស្តីពីការងារ និងប្រការ ៣៣ នៃប្រកាសលេខ ៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនមានយុត្តាធិការពិចារណាលើការទាមទារដែលមិនមាននៅក្នុងរបាយការណ៍មិនសះជានោះទេ។ បន្ថែមពីនេះទៀត ការទាមទារនេះ គឺជាការទាមទារអំពីអនាគតពីព្រោះមិនទាន់មានកម្មករនិយោជិតណាម្នាក់ត្រូវបានបញ្ឈប់ពីការងារនៅឡើយទេ គិតត្រឹមថ្ងៃសវនាការនេះ។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិតឱ្យនិយោជកបន្តកិច្ចសន្យាការងារកម្មករនិយោជិតដែលនិយោជកបានបញ្ចប់កិច្ចសន្យា ឱ្យពួកគាត់បន្តកិច្ចសន្យាការងារឡើងវិញ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើក្រុមប្រឹក្សា-អាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី១ ៖**

- បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកបន្តកិច្ចសន្យាការងារកម្មករនិយោជិតដែលនិយោជកបានបញ្ចប់កិច្ចសន្យា ឱ្យពួកគាត់បន្តកិច្ចសន្យាការងារឡើងវិញ។

ARBITRATION COUNCIL

ប្រភេទនៃសេចក្ដីបង្គាប់ ៖ សេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច

សេចក្ដីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ីខ សុទ្ធី**

ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អាន ទីរៈ**

ហត្ថលេខា ៖------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល ៖

ឈ្មោះ ៖ **គខ់ ផល្លៈ**

ហត្ថលេខា ៖ ------------------------------